**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.ប្រក

ថ្ងៃ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០២១

# ប្រកាស

## ស្តីពី

## កម្មវិធីចំណូល-ចំណាយថវិកាថ្នាក់ជាតិប្រចាំត្រីមាសទី ៣ ឆ្នាំ ២០២១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃ ព្រហស្បតិ៍ ០១រោច ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២២០/០៣៨ ចុះថ្ងៃសុក្រ ១១កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃអង្គារ ១៥កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- បានឃើញអនុក្រឹត្យលេខ ២១៧ អនក្រ.បក ចុះថ្ងៃអង្គារ ១៥កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០២០ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១
- ដោយមានការចាំបាច់ដើម្បីរក្សាតុល្យភាពនៃកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

## សម្រេច

**ប្រការ១ .-** ចំណូលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលខិតខំប្រមូលសម្រាប់ត្រីមាសទី ៣ ឆ្នាំ ២០២១ សរុបទឹកប្រាក់ចំនួន ៦ ៥៨៤ ៣០០ ០០០ រៀល (ប្រាំមួយប៊ីលានប្រាំរយប៉ែតសិបបួនលានបីរយពាន់រៀលគត់) ឬលើសកម្រិតកំណត់នេះ។ ចំណូលទាំងអស់នេះ ត្រូវបង់ចូលថវិកាថ្នាក់ជាតិឱ្យបានគ្រប់គ្រាន់និងទាន់ពេលវេលា ហើយត្រូវបានបែងចែកតាមជំពូកនៃមាតិកាថវិកានិងតាមខែដូចមានចែងក្នុងតារាងខាងក្រោមនេះ÷

ឯកតា:ពាន់រៀល

| ជំពូក | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២១ | កម្មវិធីចំណូលប្រចាំត្រីមាសទី៣ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | សរុប | ខែកក្កដា | ខែសីហា | ខែកញ្ញា | |
| **សរុបរួម** | **35.424.000** | **6.584.300** | **2.331.900** | **2.380.600** | **1.871.800** | |
| ៧២ | 20.992.000 | 2.870.100 | 910.700 | 985.400 | 974.000 | |
| ៧៣ | 11.162.000 | 2.830.200 | 956.600 | 1.133.200 | 740.400 | |
| ៧៤ | 3.270.000 | 884.000 | 464.600 | 262.000 | 157.400 | |

**ប្រការ២ .-** ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់ចំណាយប្រចាំត្រីមាសទី ៣ ឆ្នាំ ២០២១ ត្រូវបានកំណត់ស្មើនឹង ៤៩ ៥៧៣ ០០០ ០០០ រៀល (សែសិបប្រាំបួនប៊ីលានប្រាំរយចិតសិបបីលានរៀលគត់)។ ចំនួនទឹកប្រាក់នៃឥណទាននេះ ត្រូវបានបែងចែកតាមជំពូកនៃមាតិកាថវិកានិងតាមខែដូចមានចែងក្នុងតារាងខាងក្រោមនេះ÷

ឯកតា:ពាន់រៀល

| ជំពូក | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២១ | កម្មវិធីចំណាយប្រចាំត្រីមាសទី៣ | | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | សរុប | ខែកក្កដា | ខែសីហា | ខែកញ្ញា | |
| **សរុបរួម** | **164.277.000** | **49.573.000** | **14.715.000** | **15.034.000** | **19.824.000** | |
| ៦០ | 24.133.000 | 8.900.000 | 2.900.000 | 3.000.000 | 3.000.000 | |
| ៦១ | 45.079.000 | 13.700.000 | 4.500.000 | 4.600.000 | 4.600.000 | |
| ៦៤ | 72.226.000 | 21.200.000 | 5.400.000 | 5.500.000 | 10.300.000 | |
| ៦២ | 60.000 | 0 | 0 | 0 | 0 | |
| ៦៥ | 22.488.000 | 5.622.000 | 1.874.000 | 1.874.000 | 1.874.000 | |
| ៦៣ | 291.000 | 151.000 | 41.000 | 60.000 | 50.000 | |

**ប្រការ៣ .-** អាណត្តិបើកប្រាក់ ដែលចេញដោយអាណាប័កដើមខ្សែលើសពីចំនួនទឹកប្រាក់កម្រិតកំណត់ខាងលើ និងលើសពីការបែងចែកតាមជំពូកនៃថវិកាខាងលើ មិនត្រូវបានទទួលការចុះទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ ហើយក៏មិនត្រូវបានធ្វើការបើកផ្តល់ដោយបេឡារតនាគារដែរ។

**ប្រការ៤ .-** រាល់ចំណាយចាំបាច់លើសពីកម្រិតកំណត់ឥណទានដូចមានចែងក្នុងប្រការ ២ ត្រូវមានការអនុញ្ញាតពីឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៥ .-** អាណាប័កដើមខ្សែក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអ្នកទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន**

- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានហិរញ្ញកិច្ច
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ